# ស្ថានទូតអូស្ត្រាលីភ្នំពេញ

ថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០១៧

## បញ្ហាប្រឈមនាពេលអនាគតដែលទាក់ទងនឹងយុវជន ជំនាញ និងកំលាំងពលកម្ម

រដ្ឋាភិបាលអូស្ត្រាលីសហការជាមួយគំរោងផ្តួចផ្តើមរបស់វិទ្យាស្ថានបច្ចេកវិទ្យាម៉ាសាឈូសេត (SolveMIT) និងមូលនិធិអាឡាស៊ានក្នុងការអនុវត្តន៍គំរោង អំពីបញ្ហាប្រឈមនាពេលអនាគតដែលទាក់ទងនឹង យុវជន ជំនាញ និងកំលាំងពលកម្ម។

ក្នុងពេលដែលបច្ចេកវិទ្យាជួយបង្កើនការងារនិងលទ្ធភាពពលកម្ម ទន្ទឹមនឹងនេះបច្ចេកវិទ្យាក៏បានលុបបំបាត់ការងារមួយចំនួនព្រមទាំងបង្កើនគំលាតនៃជំនាញការងារ។ យុវជននាសម័យបច្ចុប្បន្ននេះកំពុងប្រឈមជាមួយហានិភ័យជាសកល ដោយសារការងារពាក់កណ្តាលអាចនឹងជំនួសដោយការវិវឌ្ឍន៍នៃបច្ចេកវិទ្យានិងម៉ាស៊ីនស្វ័យប្រវត្តិក្នុងអនាគតដ៏ខ្លី។

គំរោងផ្តួចផ្តើមថ្មីនេះនិងផ្សារភ្ជាប់គំនិតឆ្នៃប្រឌិតដើម្បី ដោះស្រាយចំពោះយុវជនដែលប្រឈមនឹងបញ្ហានេះ អោយមានឱកាសសិក្សាពីជំនាញដែលពួកគេត្រូវការដើម្បីត្រៀមខ្លួនសំរាប់តំរូវការពលកម្មនាពេលអនាគត។

ដើម្បីបង្កើនគំនិតសំរាប់យុវជនកម្ពុជាដែលមានសក្តានុពល ស្ថានទូតអូស្ត្រាលីរួមសហការជាមួយគំរោង SolveMIT និងមជ្ឍមណ្ឌល(Impact Hub) នឹងធ្វើសិក្ខាសាលាពិភាក្សា (Solve-a-thon)។

សិក្ខាសាលានេះនឹងរៀបចំនៅមជ្ឍមណ្ឌល(Impact Hub) ភ្នំពេញ នៅថ្ងៃទី២ កក្កដាចាប់ពីម៉ោង៩:០០ព្រឹក ដល់ម៉ោង១:០០រសៀល។

លោកជំទាវឯកអគ្គរាជទូតអូស្ត្រាលី **អេនជេលឡា ខកខឺរ៉េន** បានមានប្រសាសន៍ថាៈ " នេះជាឱកាសដ៏ប្រសើរមួយសំរាប់ប្រជាជនកម្ពុជា ចូលរួមជាផ្នែកមួយក្នុងគំនិតផ្តួចផ្តើមនេះ ក្នុងការដោះស្រាយបញ្ហាប្រឈមជាសកល។ លោកជំទាវបានបន្តទៀតថា សិក្ខាកាមដែលចូលរៀនក្នុងវគ្គ

សិក្ខាសាលានេះនឹងមានឱកាសជួបសំណេះសំណាល និងសហាការជាមួយ អ្នកផ្តួចផ្តើម សហគ្រិន និង អ្នកធ្វើអោយមានការផ្លាស់ប្តូរ ក្នុងការរួបរួមគ្នាបង្កើតដំណោះស្រាយថ្មីៗ" ។

រដ្ឋាភិបាលអូស្ត្រាលីបានរួមចំណែកក្នុងការផ្តល់ជំនួយជាថវិការចំនួន១.៥លានដុល្លាអូស្ត្រាលី ចំពោះគំនិតទាំងឡាយពីជុំវិញពិភពលោក ដែលមានភាពច្នៃប្រឌិតល្អបំផុតហើយផ្តល់ផលប្រយោជន៍ដល់ប្រទេសកំពុងអភិវឌ្ឍន៍ក្នុងតំបន់ឥណ្ឌូប៉ាស៊ីភិក។ ដោយឡែកមូលនិធិអាឡាស៊ាននឹងផ្តល់ជូនថវិការរហូតដល់១លានលានដុល្លាសហរដ្ឋអាមេរិក ចំពោះគំនិតណាដែលទទួលបានជ័យលាភីអំពីការគាំទ្រចំពោះយុវជនដែលមានភាពប្រឈមក្នុងពិភពលោក។

**សំរាប់បណ្តាញពត៌មាន**ដែលចាប់អារម្មណ៍ក្នុងការរាយការណ៍អំពីការសំនេះសំណាលរបស់លោកជំទាវឯកអគ្គរាជទូតអូស្ត្រាលី **អេនជេលឡា ខកខឺរ៉េន** ព្រមទាំងការបើកសិក្ខាសាលា Solve-a-thon ដែលធ្វើឡើងចាប់ពីម៉ោង៩:០០ដល់៩:៣០នាទីព្រឹក សូមអញ្ជើញចុះឈ្មោះតាមរយៈអ៊ីម៉ែលAustralian.Embassy.Cambodia@dfat.gov.au អោយបានមុនម៉ោង៥:០០ល្ងាចថ្ងៃសុក្រទី៣០ខែមិថុនា ២០១៧។